# ឯកសារសង្ខេប




## សាបសូន្យក្នុងគង្គារ ៖ មេរៀនសកលពីគំរូនៃគម្រោងថាមពលវារីអគ្គិសនី របស់ធនាគារពិភពលោក នៅក្នុងប្រទេសឡាវ។

Bruce Shoemaker and William Robichaud

នៅខែមិថុនា ឆ្នាំ២០១៨ សាកលវិទ្យាល័យ Wisconsin Press បានចេញផ្សាយសៀវភៅថ្មីមួយក្បាល ស្តីអំពីគម្រោងថាមពលវារីអគ្គិសនីណាមធឿន ២ នៃប្រទេសឡាវ។ របកគំហើញនៃសៀវភៅនេះពាក់ព័ន្ធទៅនឹងបញ្ហាចីរភាពបរិស្ថាន និងការអភិរក្សជីវៈចម្រុះ ការតាំងទីលំនៅថ្មី ការអភិវឌ្ឍន៍សង្គម គណនេយ្យភាព និងអភិបាលកិច្ច វិធីសាស្ត្រការកាត់បន្ថយភាពក្រីក្ររបស់ធនាគារពិភពលោក និងភាពសមស្របជាទូទៅ នៃគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗ ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ឯកសារនេះផ្តល់នូវសេចក្តីសង្ខេបនៃសៀវភៅ និងការរកឃើញរបស់វា។

## គំរូថ្មីមួយនៃគម្រោងវារីអគ្គិសនីនៅក្នុងប្រទេសឡាវ

### អំពីប្រវត្តិសាវតា និងបរិបទរបស់គម្រោង

ធនាគារពិភពលោកបានចូលរួមយ៉ាងសកម្មនៅក្នុងការធ្វើផែនការ ការផ្តល់ហិរញ្ញប្បទាន និងការអភិវឌ្ឍន៍គម្រោងថាមពលវារីអគ្គីសនីណាមធឿ២ (NT2) ដែលមានកម្លាំង ១០៧០ មេហ្គាវ៉ាត់នៅក្នុងប្រទេសឡាវ ចាប់តាំងពីចុងទសវត្សឆ្នាំ ១៩៨០ នៅពេលដែលគម្រោងនេះត្រូវបានសិក្សាលម្អិតជាលើកដំបូង។ ខណៈពេល

ដែលស្ថាប័នដទៃទៀតដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ក៏បានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុក្នុងការសាងសង់ទំនប់វារីអគ្គិសនីនេះ ហើយធនាគាពិភពលោកជាអ្នកដោះស្រាយបញ្ហាសំខាន់ៗ និងជាអ្នកអនុម័តគម្រោងនេះក្នុងឆ្នាំ ២០០៥ បានអនុញ្ញាតឱ្យ NT2 ដំណើរការសាងសង់។ គម្រោងអាងស្តុកទឹក[1] នេះត្រូវបានបញ្ចប់ការសាងសង់ក្នុងឆ្នាំ ២០១០ ដោយក្រុមហ៊ុនថាមពលណាមធឿន២ (NTPC) ដែលចំណាយទឹកប្រាក់អស់ ១.២៧ ពាន់លានដុល្លារអាមេរិក ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនឯកជនអាជ្ញាធរអគ្គីសនីថៃ (EGAT) ក្រុមហ៊ុនអគ្គិសនីប្រទេសបារាំង និងរដ្ឋាភិបាលឡាវ។ ភាគច្រើននៃអគ្គិសនីដែលបានមកពីទំនប់នេះ ត្រូវបានលក់និងនាំចេញទៅកាន់ប្រទេសថៃ។

NT2 ត្រូវបានគេស្នើ និងបង្កើតឡើងនៅពេលដែលធនាគារពិភពលោក និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដទៃទៀតត្រូវបានរិះគន់ចំពោះការគាំទ្រដល់គម្រោង វារីអគ្គីសនីធំៗនៅទូទាំងពិភពលោកដោយសារផលប៉ះពាល់ជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់សង្គមនិងបរិស្ថាន។ ការរិះគន់នេះបាននាំឱ្យមានការបង្កើតឡើងនូវគណៈកម្មការពិភពលោកស្តីពីទំនប់ទឹក (WCD) ដែលបានទទួលស្គាល់ពីការព្រួយបារម្ភយ៉ាងខ្លាំងអំពីទំនប់វារីអគ្គីសនីធំៗក្នុងឆ្នាំ២០០០ និងការកែទម្រង់សំខាន់ៗដែលត្រូវបានគេផ្តល់អនុសាសន៍ឱ្យរៀបចំ និងអនុវត្តក្នុងគម្រោងវារីអគ្គីសនីនេះ។

*ការលើកកម្ពស់គម្រោងវារីអគ្គិសនីគំរូថ្មីរបស់ធនាគារពិភពលោក*

ជាផ្នែកមួយក្នុងការឆ្លើយតបទៅនឹងការរិះគន់គម្រោងទំនប់ធំៗពីមុនៗ ធនាគារពិភពលោកបានកំណត់ NT2 ជាគំរូថ្មីនៃគម្រោងថាមពលវារីអគ្គិសនី ដែលជាគម្រោងមួយធ្វើឱ្យមានការវិនិយោគសាធារណៈ និងឯកជនដើម្បីកាត់បន្ថយភាពក្រីក្រ និងធ្វើឱ្យប្រជាជនដែលរងផលប៉ះពាល់ពីគម្រោង និងបរិស្ថានកាន់តែមានភាពប្រសើរឡើង។ វាត្រូវបានគេពិពណ៌នាថា ជាគម្រោងមួយដែលដើរតួយ៉ាងសំខាន់ក្នុងការឆ្លើយតបទៅនឹងតម្រូវការអគ្គិសនីដែលកំពុងកើនឡើងរបស់ប្រទេសថៃ បង្កើតប្រាក់ចំណូលសម្រាប់កាត់បន្ថយភាពក្រីក្រទូទាំងប្រទេសឡាវ ជួយថែរក្សាតំបន់ការពារដែលមានសារៈសំខាន់ជាសកល។ ធ្វើអោយប្រសើរឡើងនូវជីវិត

[1] នៅក្នុងទំនប់បង្វែរទឹកនេះ ទឹកត្រូវបានបង្វែរពីអាងទន្លេមួយទៅអាងទន្លេមួយទៀតនៅកំពស់ទាប។ នេះអាចជាការទាក់ទាញខាងសេដ្ឋកិច្ចប៉ុន្តែវាក៏ប៉ះពាល់ដល់ទន្លេពីរផងដែរ។

រស់នៅរបស់ប្រជាជនដែលរងផលប៉ះពាល់ ពង្រីកការចូលរួមរបស់សង្គមស៊ីវិលក្នុងប្រទេសឡាវ និង ជំរុញការធ្វើកំណែទម្រង់បរិយាកាសវិនិយោគរបស់ប្រទេស ខណៈពេលទទួលបានជោគជ័យក្នុងនាមជាសហគ្រាសពាណិជ្ជកម្មដែលរកប្រាក់ចំណេញ។

នៅដើមឆ្នាំ ២០១១ ធនាគារពិភពលោកបានបោះពុម្ពផ្សាយសៀវភៅមួយក្បាលដែលមានចំណងជើងថា "ការកសាងទំនប់ឱ្យកាន់តែប្រសើរ" អំពីការអភិវឌ្ឍន៍ NT2 ។ សៀវភៅនេះត្រូវបានគេបោះពុម្ពផ្សាយភ្លាមៗបន្ទាប់ពី NT2 បានចាប់ផ្តើមដំណើរការពាណិជ្ជកម្ម សៀវភៅនេះគឺជាផ្នែកមួយនៃយុទ្ធនាការទំនាក់ទំនងសាធារណៈដ៏ទូលំទូលាយរបស់ធនាគារពិភពលោកក្នុងគោលបំណងបង្ហាញអំពី NT2 ក្នុងន័យវិជ្ជមាន។ កង្វះខាតប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងការកម្រិតយ៉ាងតឹងរ៉ឹងលើសង្គមស៊ីវិលក្នុងប្រទេសឡាវ បានរារាំងការស្រាវជ្រាវឯករាជ្យដែលអាចបញ្ជាក់ ឬ បដិសេធការអះអាងរបស់ធនាគារ។ ចំណុចនេះបានអនុញ្ញាតឱ្យធនាគារពិភពលោក និងNTPCផ្សព្វផ្សាយពីរឿងរ៉ាវវិជ្ជមានរបស់ NT2 ដែលភាគច្រើនមិនត្រូវបានគេជំទាស់។

ដើម្បីឲ្យ NT2 ទទួលបានការគាំទ្រច្រើនពីអន្តរជាតិ ធនាគារត្រូវបង្ហាញថា គម្រោងនេះមានផលប្រយោជន៍ល្អបំផុត និងមានការគាំទ្រច្រើនពីប្រជាពលរដ្ឋឡាវ។ ដោយមានឧបសគ្គលើសង្គមស៊ីវិលក្នុងស្រុក ធនាគារបានស្វែងរកផ្លូវផ្សេងទៀតក្នុងការធ្វើផែនការ ការត្រួតពិនិត្យ និងការយល់ព្រមមួយផ្សេងទៀត ដែលអាចឱ្យគេមើលឃើញថាឯករាជ្យ។ នេះរួមបញ្ចូលទាំងការបង្កើតក្រុមអ្នកជំនាញ និងការចុះកិច្ចសន្យាជាមួយអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ (NGOs) ដើម្បីធ្វើការសិក្សាស្រាវជ្រាវ។

*ការត្រួតពិនិត្យដោយឯករាជ្យភាព និងភាពជឿជាក់ពីអន្តរជាតិ៖ ក្រុមអ្នកជំនាញការ (PoE)*

ក្រុមអ្នកជំនាញបរិស្ថានអន្តរជាតិ និងសង្គមនៃ NT2 បានបង្កើតឡើងក្នុងឆ្នាំ ១៩៩៧ ដែលមានអ្នកជំនាញបីរូបដែលត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ ដែលមានជំនាញខាងការតាំងទីលំនៅដ្ឋានថ្មីពីការសាងសង់ទំនប់ ជំនាញព្រៃតំបន់ត្រូពិច និងការអភិរក្សជីវចម្រុះ។ តួនាទីតាមដានត្រួតពិនិត្យរបស់ PoE ការធ្វើរបាយការណ៍ជាសាធារណៈ និងអាណត្តិនៃការប្រតិបត្តិរបស់ខ្លួនគឺជាទិដ្ឋភាពសំខាន់ និងមានលក្ខណៈច្នៃប្រឌិតរបស់គម្រោង។ ទោះជាយ៉ាងណាក៏ដោយ PoE បានធ្វើឱ្យអ្នករិះគន់ NT2 មានការភ្ញាក់ផ្អើល

យ៉ាងខ្លាំង នៅពេលដែលក្រុមនេះ បានធ្វើទស្សនកិច្ចជាលើកទី២ទៅកាន់ប្រទេសឡាវ គេបានឯកភាពទៅលើគម្រោងនេះយ៉ាងពេញទំហឹង សូម្បីតែការសិក្សាពីសង្គម និងបរិស្ថានសំខាន់ៗរបស់គម្រោងនៅមិនទាន់បានបញ្ចប់នៅឡើយ។ លើសពីនេះទៀត តាមរយៈការអនុម័តគម្រោងនៅឆ្នាំ ២០០៥ PoE នៅតែជាអ្នកគាំទ្រដ៏រឹងមាំរបស់ NT2 ។ ក៏ប៉ុន្តែ នៅពេលដែលការអនុវត្តគម្រោងបានរីកចម្រើន PoE បានបង្ហាញពីការព្រួយបារម្ភ និងការរិះគន់ជាច្រើនទៅលើកម្មវិធីបរិស្ថាន និងសង្គមរបស់ NT2 ។ ការស្រងាកចិត្តនេះបានកើតឡើង នៅឆ្នាំ ២០១៤ នៅពេលដែលលោកបណ្ឌិត Thayer Scudder ជាសមាជិករបស់ PoE បានបង្ហាញជា សាធារណៈនូវការខកចិត្តរបស់គាត់ជាមួយនឹងគម្រោងនេះ។ នៅចុងឆ្នាំ ២០១៥ PoE បានបដិសេធមិនព្រមចុះហត្ថលេខាអនុម័តលើការបិទកម្មវិធីតាំងទីលំនៅថ្មីរបស់ NT2 ដោយសារតែការព្រួយបារម្ភអំពីសមិទ្ធផល និងនិរន្តរភាពរបស់កម្មវិធីនេះ។

ខណៈដែលការអនុម័តដំបូងរបស់ PoE លើគម្រោង NT2 បានបង្ហាញថា គឺធ្វើឡើងលឿនពេក មិនទាន់គ្រប់លក្ខណ និងរបាយការណ៍រួមរបស់ PoE នៅមានភាពច្របូកច្របល់គ្នា។ របាយការណ៍ PoE គឺជាកំណត់ត្រាសាធារណៈដ៏សំខាន់មួយនៃប្រវត្តិសាស្រ្តរបស់ NT2។ អន្តរាគមន៍របស់ PoE នៅតាមដំណាក់កាលផ្សេងៗនោះ ពិតជាបានជួយដល់បរិស្ថាននិងប្រជាជនដែលរងផលប៉ះពាល់ ។ សមាជិក PoE សមនឹងទទួលបាននូវការទទួលស្គាល់ថា មានឆន្ទៈក្នុងការរិះគន់លើគម្រោងដែលពួកគេបានផ្តល់យោបល់យ៉ាងសន្ទឹកសន្ធាប់។ ទោះជាយ៉ាងណាក៏ដោយ បទពិសោធន៍នោះក៏ចង្អុលបង្ហាញពីការកំណត់លើប្រសិទ្ធភាពរបស់ក្រុមការងារដែលមកពីខាងក្រៅដែរ។ ការផ្តល់ដំបូន្មាន និងការតស៊ូមតិរបស់ក្រុមការងារឯករាជ្យនៃគម្រោង NT2 គឺជាការជំនួសតិចតួចនៃការចូលរួមពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងការឆ្លើយតបរបស់ស្ថាប័នរដ្ឋដែលត្រូវមានគណនេយ្យភាពចំពោះប្រជាជនរបស់ខ្លួន។

## ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល

ដោយមានឧបសគ្គផ្នែកនយោបាយទៅលើសង្គមស៊ីវិលក្នុងស្រុក ធនាគារពិភពលោកបានលើកទឹកចិត្តដល់អង្គការអភិវឌ្ឍន៍និងអង្គការអភិរក្សអន្តរជាតិនានាឲ្យចូលរួមក្នុងការធ្វើផែនការនិងការអនុវត្តគម្រោង។ បុគ្គលិកធនាគារបានទទួលស្គាល់ថា ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលអាចផ្តល់ព័ត៌មាន និងទស្សនៈទានសំខាន់ៗ និងលើកកម្ពស់រូបភាពវិជ្ជមានដល់ទំនប់នេះ។ បញ្ហាខ្វះខាតចំពោះវិធីសាស្រ្តនេះគឺថា

អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនៅក្នុងប្រទេសឡាវ ត្រូវបានតម្រូវឲ្យធ្វើការងារជាដៃគូជាមួយស្ថាប័នរបស់រដ្ឋាភិបាល។ ពួកគេគ្មានសិទ្ធិតំណាងឲ្យផលប្រយោជន៍របស់សហគមន៍ដែលមិនអាចនិយាយបានដោយខ្លួនឯងបាននោះឡើយ។

អ្នកអភិវឌ្ឍគម្រោងបានចុះកិច្ចសន្យាជាមួយអង្គការចំនួនបីដូចជា អង្គការឃែរ (CARE) អង្គការអភិរក្សសត្វព្រៃ (WCS) និងសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ[2] (IUCN) ដើម្បីធ្វើការស្រាវជ្រាវផ្នែកសង្គមនិងបរិស្ថាន ក្នុងការរៀបចំគម្រោងនេះ។ នៅដើមឆ្នាំ ១៩៩៦ នាយកកម្មវិធីនៃអង្គការអភិរក្សសត្វព្រៃ (WCS) នៅអាស៊ី បានទទួលស្គាល់ជាសាធារណៈលើគម្រោង NT2 ដែលការទទួលស្គាល់នេះធ្វើឲ្យមានភាពចម្រូងចម្រាស់គួរឲ្យកត់សម្គាល់។ អង្គការ CARE និង IUCN មិនបានគាំទ្រជាផ្លូវការលើគម្រោងនេះទេ ប៉ុន្តែត្រូវបានគេមើលឃើញថាដូចជាមានការគាំទ្រគម្រោងនេះ។ សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលជាច្រើនដែលជំទាស់ទៅនឹងគម្រោង NT2 យល់ឃើញថា ការគាំទ្ររបស់ WCS ក៏ដូចជាការចូលរួមរបស់អង្គការដែលជាប់កិច្ចសន្យាដទៃទៀត បានធ្វើឲ្យយុទ្ធនាការប្រឆាំងទៅនឹងគម្រោង NT2 របស់សម្ព័ន្ធខ្លួនមានភាពទន់ខ្សោយ។

អង្គការអន្តរជាតិដទៃទៀតដែលមានមូលដ្ឋាននៅប្រទេសឡាវ បានចូលរួមក្នុងកិច្ចប្រជុំនិងដំណើរការនៃការចូលរួមជាសាធារណៈ និងដោយផ្លូវការដើម្បីពិនិត្យឡើងវិញលើផែនការគម្រោងនេះ។ ក្រុមទាំងនោះយល់ថា ការចូលរួមរបស់ពួកគេហាក់ដូចជាស្ថិតនៅក្នុងបរិបទមួយដែលការសម្រេចចិត្តបានធ្វើឡើងរួចទៅហើយ ដូច្នេះការចូលរួមនេះគឺមានន័យតិចតួចណាស់។ អតីតបុគ្គលិកខ្លះយល់ថា អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិត្រូវបានគេប្រើដោយមិនសមស្រប ជំនួសឲ្យការខ្វះសង្គមស៊ីវិលក្នុងប្រទេសឡាវ។ បទពិសោធន៍របស់ NT2 បានបង្ហាញពីការប្រុងប្រយ័ត្នមួយសម្រាប់អង្គការក្រៅរដ្ឋាភិបាល ដោយលើកឡើងថា ពួកគេគួរតែយកចិត្តទុកដាក់ខ្ពស់នៅពេលមានការអញ្ជើញឱ្យចូលរួម លើការផ្តួចផ្តើមគំនិតរបស់គម្រោងអភិវឌ្ឍន៍ធំៗ ហើយការចូលរួមគួរធ្វើឡើងក្រោយពីមានការពិចារណាពេញលេញ អំពីផលប៉ះពាល់ដែលមានសក្តានុពលប៉ុណ្ណោះ។

---

[2] បើតាមបច្ចេកទេស IUCN គឺមិនមែនជាអង្គការក្រៅរដ្ឋាភិបាលនោះទេ ។

## លទ្ធផលសង្គម និងបរិស្ថាន

បញ្ហាជនជាតិដើមភាគតិច

គម្រោង NT2 មានទីតាំងស្ថិតនៅកណ្តាលប្រទេសឡាវ ជាតំបន់មួយដែលស្ថិតនៅចំណុចប្រសព្វនៃក្រុមជនជាតិភាគតិចចម្រុះនិងប្រវត្តិយូរយា រួមមាន ជនជាតិតាយ សៀម វៀតណាម ចាម ខ្មែរ និងឡាវ ដែលជាអតីតនៃរាជអាណាចក្រឡាវ និងក្រុមកុលសម្ព័ន្ធផ្សេងទៀតដែលមានវប្បធម៌ខុសៗគ្នារាប់ចាប់ពីក្រុមអ្នកប្រមាញ់រហូតដល់អ្នករស់នៅទីក្រុងដែលជឿនលឿន។ បច្ចុប្បន្នមានប្រជាពលរដ្ឋដែលមានផ្នែកជាតិពន្ធុធំៗចំនួនបីដែលរស់នៅក្នុងតំបន់គម្រោង NT2 នេះ។ ប្រហែលជាគ្មានគម្រោងណាផ្សេងទៀតនៅទ្វីបអាស៊ីនេះដែលមានការរួមផ្សំនៃប្រវត្តិសាស្ត្រនិងភាពចម្រុះជាតិសាសន៍បែបនេះទេ។ ប៉ុន្តែគម្រោងនេះបានដំណើរការដោយមិនមានការយល់ច្បាស់អំពីប្រវត្តិសាវតាទាំងនេះ។ ផលវិបាកគឺថា គម្រោងនេះមិនអាចសម្រេចគោលបំណងរបស់ខ្លួនបានក្នុងការធ្វើអោយប្រសើរឡើងដល់ជីវិតរស់នៅរបស់ជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់នោះទេ។

ការស្រាវជ្រាវនៃជាតិពន្ធុសាស្ត្រមួយចំនួនត្រូវបានធ្វើឡើងនៅចុងទសវត្សឆ្នាំ ១៩៩០ ទាក់ទងទៅនឹងគម្រោងនេះ ប៉ុន្តែត្រូវបានបញ្ឈប់ទៅវិញ។ ផ្ទុយទៅវិញ អ្នកអភិវឌ្ឍន៍គម្រោងបានផ្តោតទៅលើការរៀបចំឯកសារគោលនយោបាយគាំពារ ដែលតម្រូវដោយធនាគារពិភពលោកទៅវិញ។ តែឯកសារនោះមិនមែនជាឯកសារជំនួសឱ្យការស្រាវជ្រាវស៊ីជម្រៅនោះទេ។ ឯកសារការពារ NT2 ត្រូវបានប្រមូលចងក្រងឡើងដោយសើៗពីការប្រមូលផ្តុំព័ត៌មានតាមបែបវាយតំលៃរហ័ស។ លទ្ធផល គឺថា បង្កើនភាពងាយរងគ្រោះរបស់ជនជាតិដើមភាគតិច បានទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីគំម្រោងនេះ។

## ការតាំងទីលំនៅថ្មី និងតំបន់ខ្ពង់រាបណាកៃ

ទឹកជំនន់លើផ្ទៃដីចំនួន ៤៣០ គីឡូម៉ែត្រការ៉េ នៅលើខ្ពង់រាបណាកៃដោយអាងស្តុកទឹករបស់គម្រោង NT2 បណ្តាលឱ្យបាត់បង់ដីរបស់ជនជាតិដើមភាគតិចប្រហែល ៦៣០០គ្រួសារនៅក្នុង១៧ភូមិ។ ភូមិចំនួន១៦ភូមិក្នុងចំណោមភូមិទាំងនោះ ត្រូវតាំងទីលំនៅថ្មី។ ក្រោយពីការពិគ្រោះយោបល់មក មានការឯកភាពថាដោយស្របតាមបំណងប្រាថ្នារបស់អ្នកភូមិ ពួកគេនឹងត្រូវតាំងទីលំនៅថ្មីលើតំបន់ដែលគ្មានទឹកលិចនៅតំបន់

ខ្ពង់រាបនោះ។ កិច្ចព្រមព្រៀងសម្បទានរបស់ NT2 តម្រូវឱ្យអ្នកអភិវឌ្ឍន៍គំរោង គឺ NTPC ជួយលើកកំពស់ដល់ជីវភាពរស់នៅរបស់អ្នកភូមិដែលតាំងទីលំនៅថ្មីឲ្យល្អប្រសើរឡើង រួមទាំងការបង្កើនសមត្ថភាពរកប្រាក់ចំណូលផងដែរ។ ក្រុមហ៊ុន NTPC បានបង្កើតផែនការអភិវឌ្ឍសង្គម (SDP) ដែលបានស្នើឲ្យមាន "សសរស្តម្ភ" ចំនួន ០៩ ដើម្បីស្តារនិងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងភូមិ មានដូចជា កសិកម្ម ការចិញ្ចឹមសត្វ សហគមន៍ព្រៃឈើ ជលផលក្នុងអាងស្តុកទឹក និងសកម្មភាពក្រៅកសិកម្មជាដើម។

ជាអកុសល ការរកដីថ្មីនៅតំបន់ខ្ពង់រាបដែលមិនលិចទឹកដោយអាងស្តុកទឹក ឬ ដីដែលបានកាន់កាប់ដោយអ្នកដទៃបានបង្ហាញថាវាមានការលំបាក។ មានមូលហេតុសាមញ្ញមួយ។ នៅតំបន់ដែលត្រូវបានគេកំណត់សម្រាប់ការតាំងទីលំនៅថ្មី ដែលនៅមិនទាន់ត្រូវបានកាន់កាប់នៅឡើយ គឺជាដីគ្មានជីវជាតិ ទាំងវិស័យកសិកម្ម (ជាពិសេសការដាំដុះស្រូវ) និងការចិញ្ចឹមសត្វជាដើម។ ជាលទ្ធផល សត្វក្របីរាប់រយក្បាលរបស់ប្រជាពលរដ្ឋដែលបានតាំងទីលំនៅថ្មី ត្រូវអត់ចំណីអាហារបន្ទាប់ពីអាងស្តុកទឹកបានពេញហៀរ ហើយផលិតផលកសិកម្មនៅកន្លែងតាំងទីលំនៅថ្មីក៏ទទួលផលបានទាបជាងនៅតំបន់ភូមិចាស់ដែរ។ អ្នកភូមិដែលតាំងទីលំនៅថ្មីមិនមានលទ្ធភាពផលិតអាហារហូបចុកបានគ្រប់គ្រាន់ដើម្បីចិញ្ចឹមខ្លួនឯងទេ។ មានបញ្ហាជាច្រើនទៀតដូចជា ការចិញ្ចឹមសត្វមានការធ្លាក់ចុះច្រើន ដែលកាលពីមុនពួកគេអាចលក់សត្វចិញ្ចឹម ដែលធ្វើឲ្យពួកគេបាត់បង់ឱកាសក្នុងការរកប្រាក់ចំណូល។

ស្រដៀងគ្នានេះដែរ ការចូលរួមចំណែករបស់សហគមន៍ព្រៃឈើមានការធ្លាក់ចុះពីការគ្រោងទុកសម្រាប់ជីវភាពរស់នៅរបស់អ្នកភូមិ។ កម្មវិធីដែលត្រូវបានបង្កើតឡើងជាសមាគមន៍សហគមន៍ព្រៃឈើបានទទួលរងនូវការពន្យារពេលម្តងហើយម្តងទៀតដែលភាគច្រើន ដោយសារតែគំរូនៃការគ្រប់គ្រងព្រៃឈើដែលមិនត្រូវបានគាំទ្រនៅក្នុងបរិបទនយោបាយបច្ចុប្បន្នរបស់ប្រទេសឡាវ។ ចាប់ពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១៨ PoE បានរាយការម្តងហើយម្តងទៀតអំពីបញ្ហាសំខាន់ៗជាច្រើន ជាមួយនឹងការអនុវត្តន៍កម្មវិធីព្រៃឈើដោយកត់សម្គាល់ឃើញថា មានការធ្លាក់ចុះឆ្ងាយពីគោលដៅរបស់ខ្លួនក្នុងការផ្តល់ប្រាក់ចំណូលមួយភាគបីដល់អ្នកភូមិដែលបានតាំងទីលំនៅ។

សសរស្តម្ភមួយដែលជួយទ្រទ្រង់ជីវភាព ហើយទទួលបានជោគជ័យបំផុតនោះគឺ ជលផលពីអាងស្តុកទឹក។ ផលិតកម្មជលផលមានការកើនឡើងខ្ពស់ខណៈពេលដែលបិទទ្វារទំនប់ទឹក បន្ទាប់ពីថមថយការចាប់ត្រីនិងការរក្សាស្ថេរភាពនៃការនេសាទត្រី។ បើទោះជាទទួលបានជោគជ័យក៏ដោយ ក្តីព្រួយបារម្ភគឺនៅតែមានចំពោះនិរន្តរភាពនៃជលផលនាពេលអនាគត។ ជលផលក្នុងអាងស្តុកទឹកមានភាពផុយស្រួយហើយចាំបាច់ត្រូវឲ្យមានការថែទាំនិងការគ្រប់គ្រងយ៉ាងហ្មត់ចត់។ ផែនការ SDP ដាក់ចេញនូវវិធានការសំខាន់ៗដើម្បីកាត់បន្ថយហានិភ័យដែលគំរាមកំហែងដល់និរន្តរភាពជលផលមានដូចជា ការធានាគុណភាពទឹកតាមរយៈការបោសសំអាតជីវម៉ាសជាមុន ធានាឲ្យមានសិទ្ធិផ្តាច់មុខក្នុងការនេសាទដល់សហគមន៍តាំងទីលំនៅថ្មី និងការបង្ការការចិញ្ចឹមប្រភេទសត្វចំណែក (ប្រភេទថ្មី)។ តែជាអកុសល គោលនយោបាយទាំងនេះមិនត្រូវបានអនុវត្តស្របតាមបទដ្ឋានខ្ពស់នោះទេ។

ថ្វីបើមានហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដូចជា សាលារៀន ផ្លូវថ្នល់ គ្លីនិក និងផ្ទះថ្មីៗត្រូវបានសាងសង់សម្រាប់អ្នកភូមិដែលតាំងទីលំនៅថ្មីក្តី ក៏ភាពជោគជ័យនៃការស្តារឡើងវិញនូវជីវភាពរស់នៅ នៅតែមិនងាយស្រួល។ នៅឆ្នាំ ២០១៥ PoE បានរាយការណ៍ថា "បញ្ហាសំខាន់ៗនៅតែមាន" សម្រាប់ពួកគេជាមួយនឹងសសរស្តម្ភទ្រទ្រង់ជីវភាពទាំង៥។ ក្រុមPoE ក៏បានសម្តែងការព្រួយបារម្ភផងដែរថា ការរីកចម្រើនសំខាន់ខាងប្រាក់ចំណូលរបស់អ្នកភូមិមិនមាននិរន្តភាព ដោយសារតែប្រាក់ចំណូលគឺបានមកពីការប្រមូលផលខុសច្បាប់នៃឈើត្រូពិកនិងសត្វព្រៃនៅក្នុងតំបន់ព្រៃការពារ (ដូច្នេះហើយវាគឺជាការចំណាយលើតម្លៃនៃគោលដៅរក្សរបស់គម្រោង)។ ផលវិបាកនៃការបរាជ័យរួមក្នុងកម្មវិធីទ្រទ្រង់ជីវភាព ដើម្បីស្តារឡើងវិញប្រកបដោយនិរន្តភាពនូវជីវភាពរស់នៅរបស់ពលរដ្ឋដែលមានភាពល្អប្រសើរតិចតួច PoE បានបដិសេធមិនចុះហត្ថលេខាលើការបិទបញ្ចប់ផែនការនៃកម្មវិធីតាំងទីលំនៅថ្មីនៅចុងឆ្នាំ ២០១៥ ដែលបណ្តាលឲ្យមានការពន្យារពេលពីរឆ្នាំបន្ថែមទៀត នៃ គម្រោងនេះ។

*ការអភិរក្សជីវចម្រុះ*

តំបន់គ្របដណ្តប់នៃគម្រោងទំនប់ NT2 នេះរួមបញ្ចូលទាំងតំបន់អភិរក្សធម្មជាតិដ៏សំខាន់បំផុតមួយនៅក្នុងពិភពលោក។ តំបន់អភិរក្សជាតិណាកៃណាមធឿន (NNT) គឺជាតំបន់អភិរក្សដ៏ធំបំផុតនៅក្នុងប្រទេសឡាវ ហើយមានប្រភេទសត្វជាច្រើនដែលត្រូវបានរងការគំរាមកំហែងជាសកល។

អាងស្តុកទឹក NT2 លាតសន្ធឹងនៅតាមបណ្តោយគែមខាងលិចនៃ NNT ។ ដូច្នេះហើយបានជាតំបន់ការពារបានក្លាយជាចំណុចយកចិត្តទុកដាក់លើក្តីកង្វល់ផ្នែកបរិស្ថានអំពី NT2 និងបង្កើតនូវគោលនយោបាយការពាររបស់ធនាគារពិភពលោកលើទីជម្រកធម្មជាតិ។ ធនាគារបានទទួលយកនូវគោលដៅចំនួនពីរៈ ធានាថាផលប៉ះពាល់របស់ NT2 ទៅលើ NNT ត្រូវបានកាត់បន្ថយនិងការពារណាកៃណាមជឿន (NNT)ឲ្យកាន់តែជាការអភិរក្សបន្ថែម ដើម្បីទូទាត់សងសម្រាប់ការជន់លិចនៃខ្ពង់រាបណាកៃ។

ការពិតការគាំទ្ររបស់ធនាគារចំពោះទំនប់នេះ យ៉ាងហោចណាស់ជាគោលការណ៍ គឺទំនងជាបានរំលោភបំពានលើគោលនយោបាយទីជម្រកធម្មជាតិរបស់ធនាគារ ដែលហាមឃាត់ធនាគារពីការគាំទ្រគម្រោងដែលបំផ្លាញតំបន់ការពារយ៉ាងសំខាន់។ តំបន់ការពារ NNT បានរួមបញ្ចូលនូវពល់ខ្ពង់រាបណាកៃនៅប៉ែកខាងកើតទន្លេណាមជឿន ប៉ុន្តែក្រោយមកខ្ពង់រាបនោះត្រូវបានដកចេញពីតំបន់ការពារក្នុងឆ្នាំ ២០០០ ដើម្បីឱ្យNT2 អាចបន្តដំណើរការបាន។

សម្រាប់រយៈពេលសម្បទាន ២៥ ឆ្នាំរបស់គម្រោង NT2 ប្រាក់ចំណូល ១ លានដុល្លារក្នុង១ឆ្នាំ ពីទំនប់នេះ ត្រូវបានត្រៀមទុកសម្រាប់ការអភិរក្សលើអ្វីដែលនៅសល់របស់ NNT។ អាជ្ញាធរគ្រប់គ្រងនិងការពារទីជម្រាល (WMPA) ដែលជាទីភ្នាក់ងារថ្មីមួយរបស់រដ្ឋាភិបាលឡាវ ត្រូវបានបង្កើតឡើងដើម្បីប្រើប្រាស់មូលនិធិទាំងនេះដើម្បីការពារ NNT។ ប៉ុន្តែនៅចុងឆ្នាំ២០១៤ ក្រុមជំនាញការPoE បានរាយការណ៍អំពី "ការបរាជ័យនៃរបៀបធ្វើការងារបច្ចុប្បន្នភាពរបស់ WMPA ដើម្បីអនុវត្តកិច្ចការជាមូលដ្ឋាននៃការការពារជីវចម្រុះរបស់ទីជម្រាល" ។ នៅក្នុងឆ្នាំ ២០១៦ ពួកគេបានសរសេរទាក់ទងនឹង NNT ថា "ការបន្តអនុវត្តនូវវិធីសាស្ត្របរាជ័យ ... អាចនឹងមិនទទួលបានលទ្ធផលគួរជាទីពេញចិត្ត ឬមិនស្របតាមលក្ខខណ្ឌក្នុងសមាសធាតុ [ផ្នែកការពារបរិស្ថាន] របស់គម្រោង NT2។"

ដើម្បីឆ្លើយតបលើការរិះគន់នៃការអនុវត្តការងាររបស់ WMPA ធនាគារពិភពលោក និងរដ្ឋាភិបាលឡាវ បានរៀបចំគំរូនៃការគ្រប់គ្រងថ្មីមួយរបស់ NNT រួមទាំងការចូលរួមដោយផ្ទាល់ពីអង្គការមិនមែនរដ្ឋាភិបាល។ មិនថាការងារនេះវាដំណើរការឬយ៉ាងណា ក៏វាហាក់យឺតពេលបន្តិច ហើយត្រូវរង់ចាំមើល។ កាន់តែ

សំខាន់ជាងនេះទៅទៀតនោះសួរថា តើការបំផ្លិចបំផ្លាញបរិស្ថាននៅក្នុងតំបន់មួយ គឺជាយន្តការដែលមានប្រសិទ្ធភាព និងនិរន្តរភាពសម្រាប់ការការពារបរិស្ថាននៅកន្លែងផ្សេងទៀត ឬ យ៉ាងណា។

*បញ្ហានៅផ្នែកខាងក្រោមទំនប់*

ខណៈពេលដែលមានការយកចិត្តទុកដាក់ខ្លាំងចំពោះការតាំងទីលំនៅថ្មីនៅតំបន់ខ្ពង់រាបណាកៃ និងកិច្ចខិតខំប្រឹងប្រែងអភិរក្សនៅតំបន់ NT2 គម្រោងនេះក៏មានផលប៉ះពាល់យ៉ាងខ្លាំងនៅខ្សែទឹកផ្នែកខាងក្រោមនៅក្នុងអាងទន្លេពីរផងដែរ។ បញ្ហានេះ គឺប៉ះពាល់ខ្លាំងបំផុតនៅតាមបណ្ដោយដងទន្លេសេបាងហ្វៃ ដែលទទួលបរិមាណទឹកពីអាងស្តុកដ៏ច្រើនលើសលុប បន្ទាប់ពីទឹកហូរឆ្លងកាត់ទួប៊ីន(turbines)របស់ NT2។ ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជាង ១៥០,០០០ នាក់ គឺពឹងផ្អែកលើទន្លេនៅក្រោមទំនប់ NT2 នេះ។

នៅក្នុងឆ្នាំ ២០១៤ មានការស្រាវជ្រាវឯករាជ្យមួយពីទន្លេសេបាងហ្វៃបានបង្ហាញថា មនុស្សនៅតាមបណ្ដោយដងទន្លេនេះត្រូវបានគេបោះបង់ចោលហើយកាន់តែក្រីក្រទៅៗដោយសារគម្រោងនេះ។ អ្នកភូមិបានរាយការណ៍ថា ការចាប់ត្រីនិងសត្វផ្សេងទៀតដែលរស់នៅក្នុងទឹកមានការថយចុះយ៉ាងខ្លាំង ដោយសារមានទឹកជំនន់ច្រើនហួសប្រមាណ ធ្វើឲ្យលិចវាលស្រែនៅរដូវវស្សា កំរិតទឹកទន្លេមានការប្រែប្រួលឡើងចុះ ដែលបណ្ដាលឲ្យលិចលង់ច្បារដំណាំតាមមាត់ទន្លេ និងផលប៉ះពាល់ដទៃទៀតដែលពាក់ព័ន្ធទៅនឹងជលវិទ្យា និងគុណភាពទឹកមានការផ្លាស់ប្តូរ។

ដើមឡើយ PoE បានសរសើរ NT2 ចំពោះការបង្កើតកម្មវិធីផ្តល់សំណងផ្នែកខាងក្រោមទំនប់ដែលមានលក្ខណៈច្នៃប្រឌិត ប៉ុន្តែក្រោយមកបានរិះគន់ធនាគារពិភពលោក និង NTPC ចំពោះការបញ្ឈប់កម្មវិធីមុនពេលកំណត់។ កម្មវិធីផ្តល់សំណងមានរយៈពេលខ្លីពេក ហើយគំនិតផ្តួចផ្តើមជាច្រើនមិនទាន់គ្រប់គ្រាន់ ឬមិនសមស្រប។ តាមទស្សនៈរបស់អ្នកភូមិភាគច្រើនយល់ថា សំណងដែលផ្តល់ឲ្យដោយ NTPC មិនបានគ្រប់គ្រាន់ស្មើនឹងអ្វីដែលពួកគេបានបាត់បង់ជីវភាពរស់នៅរបស់ពួកគេឡើយ។ នៅពេលដែលធនាគារពិភពលោកបានបញ្ឈប់ការចូលរួមរបស់ខ្លួននៅក្នុងគម្រោង NT2 នៅចុងឆ្នាំ ២០១៧ បញ្ហានៅខ្សែទឹកខាងក្រោមនៅតែមិនទាន់បានដោះស្រាយបាននៅឡើយ។

ចំណូលគ្មានគណនេយ្យភាព

ការសន្យាសំខាន់មួយរបស់គម្រោង NT2 គឺថា គេអាចរកចំណូលដែលរដ្ឋាភិបាលឡាវអាចប្រើប្រាស់សម្រាប់ការកាត់បន្ថយភាពក្រីក្រថ្នាក់ជាតិបាន។ ខណៈពេលដែលគម្រោងនេះរកបានប្រាក់ចំណូលយ៉ាងច្រើន បុគ្គលិកធនាគារមានការពិបាកក្នុងការដឹងឲ្យប្រាកដថា តើប្រាក់ចំណូលរបស់គម្រោងនោះវាទៅណា។ ចំណុចនេះនាំឱ្យក្រុមវាយតម្លៃផ្ទៃក្នុងផ្ទាល់របស់ធនាគារ ធ្វើការវាយតម្លៃ NT2 ម្តងហើយម្តងទៀតថា "មិនមានការពេញចិត្តណាស់ណានោះទេ" ។

សួរថាតើ NT2 មានឥទ្ធិពលសំខាន់ប៉ុណ្ណាទៅលើការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសឡាវ នៅតែមិនដឹងនៅឡើយ។ ទោះជាយ៉ាងណាក៏ដោយ ភស្តុតាងបញ្ជាក់ថា វាមានផលប៉ះពាល់តិចជាងការរំពឹងទុក។ ឧទាហរណ៍នៅក្នុងខែតុលាឆ្នាំ ២០១៣ ក្នុងរយៈពេលវែងមួយបន្ទាប់ពីប្រាក់ចំណូលដែលបានមកពី NT2 ចាប់ផ្តើមមានលំហូរ រដ្ឋាភិបាលឡាវបានធ្លាក់ចូលក្នុងវិបត្តិសារពើពន្ធវិញម្តងទៀត ដែលយ៉ាងហោចណាស់រដ្ឋាភិបាលយឺតយ៉ាវក្នុងការបើកប្រាក់បៀវត្សយឺតបីខែដល់គ្រូបង្រៀនរបស់ខ្លួន។ ភ្នាក់ងារសវនកម្មផ្ទៃក្នុងមួយរបស់រដ្ឋាភិបាលឡាវបានចេញរបាយការណ៍ក្នុងឆ្នាំ២០១៥ ដែលមានកំណត់ត្រានៃការកេងបន្ទំថវិការបស់រដ្ឋាភិបាល។ ថ្វីបើមានអត្រាកំណើនខ្ពស់ជាទូទៅក៏ដោយ ក៏ប្រទេសឡាវបានដើរថយក្រោយលើគោលដៅដែលបានសន្យាជាយូរមកហើយរបស់ខ្លួន ក្នុងការចាកចេញពីប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចបំផុតនៅឆ្នាំ ២០២០ ។ នៅក្នុងឆ្នាំ ២០១៧ ដំណើរការនៃការអនុញ្ញាតិឡើងវិញនៃថវិកាសម្រាប់មូលនិធិកាត់បន្ថយភាពក្រីក្រ ដែលត្រូវបានបង្កើតឡើងជាផ្នែកមួយនៃចំណូលដែលបានមកពី NT2 ចូលទៅក្នុងការកាត់បន្ថយភាពក្រីក្របានបង្ហាញថា ផ្នែកមួយយ៉ាងធំនៃមូលនិធិនេះ គឺនៅបានមកពីការបរិច្ចាគពីម្ចាស់ជំនួយអន្តរជាតិ។

ធនាគារពិភពលោកមានកាតព្វកិច្ចក្នុងការបញ្ជាក់បង្ហាញថា ចំណូលរបស់ NT2 គឺជាវិភាគទានមួយក្នុងការធ្វើឲ្យប្រទេសឡាវមានភាពរីកចំរើនឡើង ក៏ប៉ុន្តែរហូតមកទល់ពេលនេះ នៅតែមិនទាន់អាចធ្វើបាននៅឡើយទេ។

## កេរ្តិ៍តំណែលរបស់ណាមធឿន២ (NT2)

ការបរាជ័យរហូតមកទល់ពេលបច្ចុប្បន្ននេះរបស់ NT2 គឺការសន្យាថា ផ្តល់អត្ថប្រយោជន៍ដល់ផ្នែកសង្គមនិងបរិស្ថាន ដែលមានផលប៉ះពាល់យ៉ាងខ្លាំងនៅថ្នាក់ជាតិនិងថ្នាក់តំបន់។ ដោយសារតែ NT2 ត្រូវបានប្រកាសជាគំរូថ្មីក្នុងសកលលោក ភាពបរាជ័យរបស់គម្រោងក៏ផ្តល់នូវមេរៀនជាច្រើនផងដែរ។

*ការដឹកនាំដោយរបៀបសាធារណៈ និងការចូលរួមនៅក្នុងប្រទេសឡាវ*

អ្នកគាំទ្រ NT2 បានអះអាងថា គម្រោងនេះនឹងអាចធ្វើឱ្យផ្លាស់ប្តូរផ្នត់គំនិតរបស់ស្ថាប័ននានា ដែលនឹងមានឥទ្ធិពលទៅលើការដឹកនាំដោយរបៀបសាធារណៈនៅក្នុងប្រទេសឡាវ មិនត្រឹមតែនៅក្នុងតំបន់ដែលរងផលប៉ះពាល់ពីគម្រោងប៉ុណ្ណោះទេ ប៉ុន្តែនៅទូទាំងប្រទេស។ អ្នកគាំទ្រ NT2 បានធ្វើការប៉ាន់ប្រមាណថា តាមរយៈការប្រើប្រាស់គម្រោងដើម្បីពង្រឹងក្របខ័ណ្ឌច្បាប់និងបទបញ្ញាតិជាតិ ប្រទេសនេះនឹងដើរឆ្ពោះទៅរកសង្គមមួយដែលមានការបើកចំហរ និងការអភិវឌ្ឍន៍មួយដែលមានការទទួលខុសត្រូវលើផ្នែកសង្គមនិងបរិស្ថាន។

ក្រុមអ្នកគាំទ្រ NT2 បានធ្វើការវាយតម្លៃហួសប្រមាណពីផលប៉ះពាល់ទូទាំងប្រទេសនៃកំណែទម្រង់ស្ថាប័នជាផ្លូវការ ហើយមើលរំលងចំពោះភាពចាំបាច់នៃស្ថាប័នក្រៅផ្លូវការ បើទោះណាជាស្ថាប័នក្រៅផ្លូវការនៅតែមានសារៈសំខាន់ជាង នៅក្នុងប្រទេសឡាវក៏ដោយ។ ថ្វីបើប្រទេសឡាវបានឃើញពីការប្រែប្រួលវិជ្ជមានមួយចំនួនចាប់តាំងពីមានគម្រោង NT2 ក៏ដោយក៏បញ្ហាទាំងនេះនៅជាប់ជំពាក់ទៅនឹងកត្តាសេដ្ឋកិច្ចនយោបាយនិងសង្គមផ្សេងទៀត ជាជាងកំណែទម្រង់ស្ថាប័នផ្លូវការ តាមរយៈគម្រោង NT2 នេះ។ លើសពីនេះទៀត មិនមែនការផ្លាស់ប្តូរទាំងអស់នោះសុទ្ធតែបានបញ្ជាក់ថាមាននិរន្តរភាពនោះទេ។

អ្នកគាំទ្រ NT2 ជាពិសេសធនាគារពិភពលោក បានផ្តោតសំខាន់ទៅលើស្ថាប័នផ្លូវការនៅក្នុងបរិបទអន្តរជាតិនិងនៅទីក្រុង ដែលបណ្តាលឱ្យមានទស្សនៈខុសគ្នាអំពីឱកាសសម្រាប់ការពិភាក្សា និងការដឹកនាំដោយរបៀបសាធារណៈនៅក្នុងប្រទេសឡាវ។ លទ្ធផល គឺការព្យាករណ៍បែបសាមញ្ញនិងមិនប្រាកដនិយមមួយនៃការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ច នយោបាយ និងសង្គម ដែលនឹងកើតចេញពីគម្រោង។ ថ្វីត្បិតតែគម្រោង

NT2 បានជួយបើកទ្វារសម្រាប់គម្រោងវារីអគ្គីសនីដែលទទួលបានមូលនិធិពីផ្នែកឯកជននៅក្នុងប្រទេសឡាវក៏ដោយ ក៏វាមិនបានបង្ហាញពីគំរូ ដែលជំរុញឱ្យមានសង្គមមួយដែលការចូលរួមកាន់តែប្រសើរនោះទេ។

*តួនាទីរបស់ប្រទេសថៃនៅក្នុង ណាំធឿន 2 (NT2)*

ផ្នែកមួយដ៏សំខាន់ក្នុងរឿង NT2 គឺទាក់ទងនឹងប្រទេសថៃដែលជាអ្នកជិតខាង ដែលជាអ្នកទិញភ្លើង/អគ្គិសនីយ៉ាងច្រើនពីគម្រោងNT2។ ក្នុងអំឡុងពេលធ្វើផែនការគម្រោង ចំណុចសំខាន់នៃការខ្វែងគំនិតគ្នានោះគឺថា តើប្រទេសថៃត្រូវការថាមពលអគ្គីសនីពី គម្រោង NT2 ឬក៏អត់។ ផ្ទុយពីការព្យាករណ៍របស់ធនាគារពិភពលោក ប្រទេសថៃបានរក្សាកំរិតអគ្គិសនីបំរុងខ្ពស់ ដែលមានកំរិតខ្ពស់ជាងលើស ១៥% សម្រាប់ការផលិតថាមពល។ ប្រទេសថៃអាចធ្វើបានយ៉ាងងាយស្រួលដោយមិនចាំបាច់មានអគ្គីសនីពី NT2។ ការវិនិយោគលើសលុបក្នុងការផលិតថាមពលនៅក្នុងប្រទេសថៃ មានន័យថាអ្នកប្រើប្រាស់អគ្គិសនីក្នុងប្រទេសថៃបានបន្តចំណាយច្រើនលើសពីអ្វីដែលពួកគេត្រូវបង់ លើតម្លៃអគ្គិសនី។

គំរូអាជីវកម្មថ្មីរបស់ធនាគារពិភពលោកចំពោះការផ្តល់ហិរញ្ញប្បទានដល់គម្រោងថាមពលវារីអគ្គិសនីដែលផ្តោតលើការដាវថាមពលមិនមានតម្លាភាព និងកិច្ចព្រមព្រៀងសម្បទាន និងសម្របសម្រួលដោយការឧបត្ថម្ភធនពីរដ្ឋ បានផ្តល់ការការពារនិងការធានាដល់វិនិយោគិនឯកជន និងអ្នកផ្តល់ប្រាក់កម្ចីពាណិជ្ជកម្ម ប៉ុន្តែមិនបានផ្តល់ការការពារ និងការធានាចំពោះប្រជាពលរដ្ឋដែលរងផលប៉ះពាល់និងអ្នកបង់ពន្ធអាករនោះទេ។ ចំណុចនេះបានជះឥទ្ធិពលយ៉ាងខ្លាំងលើ កិច្ចព្រមព្រៀងផ្នែកថាមពលវារីអគ្គីសនីឯកជនជាបន្តបន្ទាប់មកទៀត រវាងប្រទេសថៃនិងប្រទេសឡាវ។ ក្នុងករណីគម្រោង NT2 ការឆ្លើយតបរបស់ធនាគារចំពោះ បញ្ហាដែលមិនអាចបញ្ចៀសបាន ឬមានភាពតឹងតែងនោះ គឺការផ្តល់ដោយផ្ទាល់ ឬតាមរយៈភាពជាដៃគូ ជាមួយម្ចាស់ជំនួយដទៃទៀត នៃការផ្តល់ជំនួយនិងកម្ចីច្រើនបន្ថែមទៀតដល់រដ្ឋាភិបាលឡាវ។ លទ្ធផលគឺថា ការឧបត្ថម្ភធនជាសាធារណៈនិងបំណុល ត្រូវបានកត់ត្រា/រក្សាទុកដាច់ដោយឡែកពីតារាងតុល្យការរបស់ក្រុមហ៊ុន NTPC។ ការបែងចែកដាច់ដោយឡែកពីគ្នាជាលក្ខណៈស្ថាប័ននៃប្រាក់ចំណូលពិតប្រាកដពីគម្រោងទំនប់វារីអគ្គិសនី តម្លៃនិងការទទួលខុសត្រូវរបស់គម្រោង នៅក្នុងបរិបទមួយដែលការប្រឆាំងជំទាស់ជាសាធារណៈទៅនឹងម្រោងទាំងនេះនៅក្នុងប្រទេសឡាវ មិនត្រូវបានអនុញ្ញាតនោះ បានបង្កើតជាបរិយាកាស

ដ៏ទាក់ទាញមួយសម្រាប់អ្នកផ្តល់ហិរញ្ញប្បទានឯកជនលើគម្រោងវារីអគ្គិសនី និងអ្នកអភិវឌ្ឍវិស័យវារីអគ្គីសនី-និងពង្រីករហូតដល់គម្រោងដែលមិនបានទទួលការជួយឧបត្ថម្ភធនគួរឲ្យកត់សម្គាល់ច្រើន ដូចគម្រោង NT2។

ទំនប់ NT2 ត្រូវបានគ្រប់គ្រងដោយផ្អែកលើតម្រូវការថាមពលអគ្គីសនីរបស់ប្រទេសថៃ ជាពិសេសគឺតម្រូវការសម្រាប់ម៉ាស៊ីនត្រជាក់នៅក្នុងទីក្រុងបាងកក។ ចំណុចនេះហើយដែលធ្វើឱ្យទំនប់ត្រូវបើកនិងបិទ (ដំណើរការ) ហើយទឹកត្រូវបានបញ្ចេញឬក៏ទប់ពីទន្លេសេបាងហ្វៃ ផ្អែកទៅលើតម្រូវការអគ្គិសនីនៅប្រទេសថៃ ជាជាងគិតពីផលប្រយោជន៍បរិស្ថាននៃរបបលំហូរទឹក។ លទ្ធផលនៃការប្រែប្រួលខ្លាំងពីលំហូរទឹកនៅក្នុងតំបន់ទន្លេសេបាងហ្វៃបានបណ្តាលឱ្យមានការរំខាន និងខាតបង់ដល់ជីវភាពរស់នៅរបស់អ្នកភូមិឡាវដែលពឹងផ្អែកលើទន្លេនោះ។

បណ្តាញថាមពលក្នុងតំបន់ថៃ - ឡាវ ត្រូវបានរៀបចំឡើងដើម្បីឆ្ពោះទៅបម្រើលើតម្រូវការប្រើប្រាស់ខ្ពស់ ដោយមិនគិតដល់ផលប៉ះពាល់នៃការផលិត ដែលនៅឆ្ងាយនោះទេ (អ្នកប្រើនៅថៃ ការផលិតភ្លើងធ្វើនៅឡាវ)។ អ្នកប្រើប្រាស់ភ្លើងនៅថៃ EGAT រដ្ឋាភិបាលឡាវ និងធនាគារអន្តរជាតិដែលគាំទ្រគម្រោង NT2 នៅតែមានទំនាក់ទំនង ចំពោះបញ្ហាវិសមភាពជាមួយអ្នកភូមិដាច់ស្រយ៉ាលនៅក្នុងប្រទេសឡាវ។

ការជំនួសមួយនៃទំនាក់ទំនងមិនស្មើភាពគ្នានេះ គឺការទាញយកអត្ថប្រយោជន៍ពីកំណើនសក្តានុពលនៃថាមពលពន្លឺព្រះអាទិត្យ ដែលត្រូវ(ម៉ាច់)ទៅនឹងតម្រូវការអគ្គិសនីប្រចាំថ្ងៃរបស់ថៃ លើផ្នែកម៉ាស៊ីនត្រជាក់ និងទិន្នផលទាញពីថាមពលពន្លឺព្រះអាទិត្យ ដែលស្របទៅអាកាសធាតុក្តៅនិងមានពន្លឺព្រះអាទិត្យ។ ចំណុចនេះនឹងអនុញ្ញាតិឱ្យបណ្តាញអគ្គីសនី បែបអេកូឡូស៊ីនិងសង្គមកាន់តែល្អប្រសើរ គឺបណ្តាញមួយដែលពឹងផ្អែកតិចតួចទៅលើការអភិវឌ្ឍទំនប់វារីអគ្គិសនីនៅក្នុងប្រទេសឡាវ។ ផលប្រយោជន៍មួយនៃប្រព័ន្ធបែបនេះនឹងអាចផ្លាស់ប្តូរនូវរបៀបដែលអ្នកប្រើអគ្គិសនីនៅប្រទេសថៃ មានទំនាក់ទំនងទៅនឹងគម្រោងដូចជាគម្រោងNT2 និងអ្នកភូមិនានាដែលពឹងផ្អែកលើលំហូរអេកូឡូស៊ីនៃទន្លេរបស់ពួកគេ។

*ការលើកបង្ហាញពីទំនប់ ៖ ណាំធឿន 2 (NT2) និងតួនាទីរបស់ខ្លួនក្នុងការបង្កើតគោលគំនិតស្ដីពី "ថាមពលវារីអគ្គិសនីប្រកបដោយនិរន្តរភាព"*

*នៅពេលដែលថាមពលវារីអគ្គិសនីខ្នាតធំ ប្រឈមនឹងវិបត្តិលើធាកអន្តរជាតិនៃភាពស្របច្បាប់របស់ខ្លួន ទាំងធនាគារពិភពលោក និងឧស្សាហកម្មវារីអគ្គិសនីឯកជន ស្វែងរកបង្ហាញថា គម្រោងNT2ជាគំរូថ្មីជាមួយ ដែលផ្តល់អត្ថប្រយោជន៍យ៉ាងសំខាន់ផ្នែកសង្គម និងបរិស្ថាន។ "ការបង្ហាញ" របស់គម្រោងNT2នេះបានជួយជំរុញលើកទឹកចិត្តឲ្យមានគោលគំនិតថ្មីមួយស្តីពី "ថាមពលវារីអគ្គិសនីប្រកបដោយនិរន្តរភាព"។ ប៉ុន្តែស្ថានភាពរបស់គម្រោង NT2 ដែលជាគម្រោងគំរូមួយនោះ បច្ចុប្បន្នត្រូវបានក្លាយជាសំណួរមួយ មិនត្រឹមតែដោយសារតែការបរាជ័យរបស់គម្រោងក្នុងការសម្រេចបាននូវការសន្យាប្រកបដោយមហិច្ឆតារបស់ខ្លួនផ្នែកសង្គមនិងបរិស្ថានប៉ុណ្ណោះទេ ប៉ុន្តែក៏ជាសំណួរមួយក្រោយពីមានការអភិវឌ្ឍន៍ទំនប់វារីអគ្គីសនី NT2 នៅក្នុងប្រទេសឡាវផងដែរ។ ឥឡូវនេះ NT2 ក្លាយជាអ្វីមួយដែលគេហៅថា ជាទង្វើដែលខុសសម័យកាល។ រលកថ្មីនៃឧស្សាហកម្មថាមពលវារីអគ្គិសនី បានរីកដុះដាលឡើងនិងគាំទ្រដោយក្រុមហ៊ុនសាងសង់ និង អ្នកផ្តល់ហិរញ្ញប្បទាន ដែលភាគច្រើនមកពីប្រទេសថៃ ចិន និងវៀតណាម ដែលភាគច្រើននៃក្រុមហ៊ុនទាំងនេះអនុលោមទៅនឹងក្របខ័ណ្ឌបរិស្ថាននិងសង្គមដែលមានកម្រិតខ្សោយ ហើយមិនសូវមានតម្លាភាព និងគណនេយ្យភាព។*

*ទោះបីជាយ៉ាងនេះក៏ដោយ ក៏ធនាគារពិភពលោក និងរដ្ឋាភិបាលដែលជាអតិថិជនរបស់ធនាគារនេះនៅតែចង់បានទំនប់វារីអគ្គីសនីធំៗ ដោយយកលេសក្នុងនាមជាការអភិវឌ្ឍន៍អន្តរជាតិ។ គម្រោង NT2 បានដើរតួ និងនៅតែបន្តការដើរតួ ក្នុងតួនាទីមួយដ៏សំខាន់នៅក្នុងការផ្សព្វផ្សាយនេះ។ ថ្មីៗនេះ ខណៈពេលដែលវារីអគ្គីសនីធំៗ ស្វែងរកនូវការបង្ហាញថាខ្លួនអាចទទួលបានហិរញ្ញប្បទានសំរាប់បំរែបំរួលអាកាសធាតុ "វារីអគ្គិសនីប្រកបដោយនិរន្តរភាព" ត្រូវបានឧស្សាហកម្មវារីអគ្គិសនីប្រកូកប្រកាសថាជាភស្តុតាងនៃការផ្លាស់ប្តូររបស់ឧស្សាហកម្ម។ ទន្ទឹមនឹងនេះដែរ ប្រទេសមីយ៉ាន់ម៉ា គឺជាទីផ្សារថ្មីដែលកំពុងរីកដុះដាលសម្រាប់វិស័យថាមពលវារីអគ្គីសនីធំៗ ហើយឧស្សាហកម្មវារីអគ្គិសនីគឺកំពុងព្យាយាមបង្ហាញនូវនិរន្តភាពរបស់ខ្លួននៅទីនោះផងដែរ។ នៅទីនេះ ក្រុមសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិរបស់ធនាគារពិភពលោក គឺជាអ្នកដើរតួដ៏សំខាន់ក្នុងការ*

ស្នើសុំគំនិតអំពីថាមពលវារីអគ្គិសនីដែលមាននិរន្តរភាព ដោយផ្អែកលើបទពិសោធន៍របស់ខ្លួននៅក្នុងប្រទេសឡាវ។

ការចងក្រង NT2 ជាគំរូមួយ បានជួយដល់ឧស្សាហកម្មទំនប់វារីអគ្គិសនីខ្នាតធំ ហើយសម្រេចរៀបចំឡើងវិញនូវវារីអគ្គិសនីឲ្យលើសពី NT2 ដែលភាគច្រើន បានធ្វើឱ្យមាន "អាជីវកម្មដូចសព្វមួយដង" ឬ "វិធីសាស្ត្រអាជីវកម្មល្អប្រសើរជាងមុន" ។ ប្រសិនបើមានការផ្លាស់ប្តូរថាមពលប្រកបដោយនិរន្តរភាពបន្ថែមទៀត វាជាការសំខាន់ក្នុងការរៀបគម្រោងឡើងវិញនូវការជជែកវែកញែកមួយឲ្យលើសពីថាមពលវារីអគ្គិសនីប្រកបដោយនិរន្តរភាព និងរកមើលការវាយតម្លៃជម្រើសថាមពលដ៏ទូលំទូលាយ ព្រមទាំងពិចារណាយ៉ាងហ្មត់ចត់ នូវអំណះអំណាងកាន់តែរឹងមាំឡើងសម្រាប់បច្ចេកវិទ្យា ថាមពលករកើតឡើងវិញបាន ការគ្រប់គ្រងផ្អែកលើតម្រូវការ និងប្រសិទ្ធិភាពថាមពល។

## ការសន្និដ្ឋាន

ជាងដប់ឆ្នាំបន្ទាប់ពីអាងស្តុកទឹក NT2 បានចាប់ផ្តើមពេញ មានភស្តុតាងជាច្រើនដែលថាគម្រោងនេះបានសម្រេចនូវគោលដៅសង្គម និងបរិស្ថានមួយចំនួនរបស់ខ្លួន។ ធនាគារពិភពលោក និងឧស្សាហកម្មថាមពលវារីអគ្គិសនីអន្តរជាតិបានលើកស្ទួយនូវដំណើររឿងនៃជោគជ័យរបស់គម្រោង NT2 ជាជាងគំរូដែលទទួលបានជោគជ័យពិតប្រាកដ។ អ្វីដែលចាំបាច់សម្រាប់យុទ្ធនាការទំនាក់ទំនងជាសាធារណៈ គឺជាការទទួលស្គាល់របស់ធនាគា ទាំងខ្លួនឯងនិងសាធារណៈនូវភាពបរាជ័យរបស់ NT2 ដែលបន្តដោយកិច្ចខិតខំប្រឹងប្រែងដោយស្មោះនិងដោយនិរន្តរភាពដើម្បីជួសជុលការខូចខាតនេះ។ ធនាគារគួរតែផ្តោតលើការធ្វើវិសោធនកម្មមុនពេលចាប់ ផ្តើមគម្រោងគំរូថ្មីមួយទៀត។

តើអ្វីដែលជាឫសគល់នៃអ្វីដែលបានកើតឡើងនៅក្នុង NT2 ហើយអ្វីដែលបានរៀនសូត្រកន្លងមក? ទីមួយធនាគារបានបង្ហាញគំរូថ្មីនៃ NT2 ថាជាគម្រោងដែលមានហានិភ័យខ្ពស់-មានការទទួលបានផលមកវិញខ្ពស់ និងបានដាក់ការធានាលើហានិភ័យផ្នែកនយោបាយដើម្បីការពារវិនិយោគិនឯកជនរបស់ NT2 ពីហានិភ័យដល់ដើមទុនរបស់ពួកគេ។ ផ្ទុយទៅវិញ ប្រជាពលរដ្ឋនិងទឹកទន្លេងទាំងឡាយដែលប្រឈមនឹងហានិភ័យសង្គមនិងបរិស្ថានពី NT2 មិនទទួលបានការធានាស្មើគ្នាក្នុងការការពារនោះទេ។ ប្រហែលជាច្រើន

ជាងកន្លងទៅទៀតទាំងអស់ ទិសដៅដំបូងរបស់ធនាគារគឺបាញ់ឆ្ពោះទៅអ្នកវិនិយោគរបស់គម្រោង ជាជាងសហគមន៍មូលដ្ឋាននិងបរិស្ថាន ដែលបានបង្ហាញចំពោះលទ្ធផលដែលខកចិត្តផ្នែកសង្គមនិងបរិស្ថាន ដែលបានកើតឡើងបន្តបន្ទាប់មកទៀត។

NT2 បានក្លាយទៅជាគំរូមួយនៃគំរូមួយដទៃទៀត៖ ដែលជាគំរូយ៉ាងលំបាកបំផុត (ហើយប្រហែលជាមិនអាចទៅរួច) នៃការស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ី វប្បធម៌ជនជាតិដើមភាគតិច និងជីវភាពរស់នៅដែលត្រូវបានរំខានដោយគម្រោងហេដ្ឋាចនាសម្ព័ន្ធធំៗ។ វាមានដែនកំណត់លើរបៀបដែលអាចសម្រេចបានដូចជាតាមរយៈការសិក្សាស្រាវជ្រាវ កិច្ចព្រមព្រៀងនានា ទីប្រឹក្សា មូលនិធិ និងបំណងផ្សេងៗទៀត។ មិនមែនការខូចខាតទាំងអស់សុទ្ធតែអាចជួសជុលបាននោះទេ ហើយក៏មិនមែនផលប៉ះពាល់ទាំងអស់អាចត្រូវបានកាត់បន្ថយនោះដែរ។ បញ្ហាប្រឈមទាំងនោះត្រូវបានរួមផ្សំគ្នាឡើងខណៈៈដែលគម្រោងទាំងនោះត្រូវបានគេព្យាយាមធ្វើឡើងក្នុងប្រទេសដែលពុំមានបរិយាកាសអំណោយផលដូចជា បញ្ហាអភិបាលកិច្ចទន់ខ្សោយនិងមានតម្លាភាពតិចតួច។

បទពិសោធន៍របស់គម្រោងNT2 ក៏បានបង្ហាញឲ្យឃើញផងដែរថា ប្រសិនបើការការពាររបស់ធនាគារពិភពលោកមិនរឹងមាំគ្រប់គ្រាន់ ឬពិបាកក្នុងការអនុវត្តន៍ ជាពិសេសនៅក្នុងប្រទេសដូចជាប្រទេសឡាវ ជាដើម។ ឥឡូវមានសំណួរមួយផុសឡើងគឺថា នៅពេលដែលប្រឈមមុខនឹងសម្ពាធកាន់តែខ្លាំង តើធនាគារពិភពលោកឆ្លើយតបទៅនឹងបញ្ហាទាំងនោះយ៉ាងដូចម្តេច? តើធនាគានឹងចូលរួមធ្វើឲ្យអ្នកក្រីក្រកាន់តែរងផលប៉ះពាល់ និងទំលាក់ចុះ/ធ្វើឲ្យកម្សោយនូវគោលនយោបាយការពាររបស់ខ្លួន?

ដើម្បីឲ្យ NT2 មានការផ្លាស់ប្តូរ ចាំបាច់បំផុតត្រូវមានការផ្លាស់ប្តូរនៅក្នុងធនាគារពិភពលោកខ្លួនឯងនិងដៃគូហិរញ្ញវត្ថុរបស់ខ្លួនជាមុនសិន។ ស្ថាប័នទាំងនេះត្រូវតែផ្តល់អាទិភាពដល់សហគមន៍ និងបរិស្ថានមុននឹងគិតពីតម្រូវការរបស់វិនិយោគិន ហើយគួរតែនៅឲ្យឆ្ងាយពីគម្រោងហិរញ្ញប្បទានធំៗ ក្នុងស្ថានភាពមួយដែលខ្វះលក្ខខណ្ឌចាំបាច់ ដើម្បីធានាឲ្យមាននូវចំណុចវិជ្ជមាន លទ្ធផលដែលមាននិរន្តរភាព ជាពិសេសចំពោះប្រជាជនដែលរងផលប៉ះពាល់ និងតំបន់ដែលមានតម្លៃក្នុងការអភិរក្សខ្ពស់។

# អក្សរកាត់

EGAT អាជ្ញាធរផលិតអគ្គិសនីរបស់ប្រទេសថៃ

IUCN សហភាពអន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ

NNT ណាកៃ ណាមធឿន (តំបន់ការពាររបស់ជាតិ)

NT2 គម្រោងវារីអគ្គីសនីណាមធឿន 2

NTPC ក្រុមហ៊ុនថាមពលណាមធឿន 2

NGO អង្គការមិនមែនរដ្ឋាភិបាល

PoE ក្រុមអ្នកជំនាញអន្តរជាតិផ្នែកបរិស្ថាននិងសង្គម

SDP ផែនការអភិវឌ្ឍន៍សង្គម

WCD គណៈកម្មាធិការពិភពលោកស្តីពីទំនប់ទឹក

WCS សង្គមអភិរក្សសត្វព្រៃ

WMPA ភ្នាក់ងារការពារនិងគ្រប់គ្រងទីជម្រាល